## បេសសកម្មរបស់យើង

**ការផ្លាស់ប្ដូរការរស់នៅ** ដោយការផ្ដល់ការគាំទ្រ និងជំរុញភាពជាដៃគូដែលផ្ដល់អំណាយឱ្យមនុស្សរស់នៅតាមជីវិតដែលពួកគេចង់បាន។

## តម្លៃរបស់យើង

**ការគោរព** ដែលទទួលបានតាមរយៈការទទួលស្គាល់ជាវិជ្ជមាននៃសារៈសំខាន់របស់បុគ្គលទាំងអស់

**ការធ្វើផែនការផ្ដោតលើបុគ្គល** ដើម្បីគាំទ្របុគ្គលនីមួយៗ ឱ្យឈានដល់សក្ដានុពលរបស់គាត់ ឬនាង

**ភាពជាដៃគូ** រវាង DDA និងអតិថិជន គ្រួសារ និងអ្នកផ្ដល់សេវា ដើម្បីអភិវឌ្ឍ និងទ្រទ្រង់ការគាំទ្រ និងសេវាកម្មដែលត្រូវការ និងចង់បាន

**ការចូលរួមក្នុងសហគមន៍**ដោយផ្ដល់អំណោចឱ្យបុគ្គលម្នាក់ៗដែលមានពិការភាពខាងការលូតលាត់ឱ្យក្លាយជាផ្នែកនៃកម្លាំងពលកម្ម និងរួមចំណែកជាសមាជិកសង្គម។



## ចក្ខុវិស័យរបស់យើង

**ការគាំទ្របុគ្គលម្នាក់ៗ** ឱ្យរស់នៅ រួមចំណែក និងចូលរួមក្នុងសហគមន៍របស់ពួកគេ

**បន្តពង្រឹងការគាំទ្រ** ដល់ទាំងគ្រួសារកុមារ និងមនុស្សពេញវ័យ

**ការតម្រូវតាមបុគ្គលចំពោះការគាំទ្រ** ដែលនឹងផ្ដល់អំណាចដល់បុគ្គលដែលមានពិការភាពខាងការលូតលាស់ដើម្បីយល់ដឹងពីសក្ដានុពលល្អបំផុតរបស់ពួកគេ

**ការកសាងផែនការគាំទ្រផ្អែកលើតម្រូវការ** និងភាពខ្លាំងរបស់បុគ្គល និងគ្រួសារ និង

**ការភ្ជាប់ពាក់ព័ន្ធបុគ្គលម្នាក់ៗ បណ្ដាគ្រួសារ** អ្នកផ្ដល់សេវាក្នុងតំបន់ ដៃគូរដ្ឋាភិបាលសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីបន្តពង្រឹងប្រព័ន្ធគាំទ្ររបស់យើង។

## ទាក់ទងយើង

ចូលមើលលើបណ្ដាញ ៖
*dshs.wa.gov/dda/service-and-information-request*

ស្វែងរកការិយាល័យ ៖
*dshs.wa.gov/DDA/dda/ find-an-office*

ទូរស័ព្ទមកយើង ៖

| ខោនធី | ទូរស័ព្ទ |
|---|---|
| Chelan, Douglas, Ferry, Grant, Lincoln, Okanogan, Pend Oreille, Spokane, Stevens | (800) 319-7116 |
| Adams, Asotin, Benton, Columbia, Franklin, Garfield, Grant, Kittitas, Klickitat, Walla Walla, Whitman, Yakima | (866) 715-3646 |
| Island, San Juan, Skagit, Snohomish, Whatcom | (800) 567-5582 |
| King | (800) 974-4428 |
| Kitsap, Pierce | (800) 735-6740 |
| Clallam, Clark, Cowlitz, Grays Harbor, Jefferson, Lewis, Mason, Pacific, Skamania, Thurston, Wahkiakum | (888) 707-1202 |

*អ្នកដែលត្រូវការជំនួយជាមួយបណ្ដឹង ឬសហគមន៍អាចទូរស័ព្ទទៅសេវាបញ្ជូនបន្តទូរគមនាគមន៍វ៉ាស៊ីនតោនដោយចុចទៅលេខ 7-1-1 ឬ 1-800-833-6388 (TTY)។*

*វាគឺជាគោលការណ៍របស់ DSHS ដែលបុគ្គលម្នាក់ៗនឹងមិនត្រូវបានរើសអើងប្រឆាំង (ក្នុងការងារ ឬសេវាកម្ម) ព្រោះតែពូជសាសន៍ ពណ៌សម្បុរ សាសនា ជំនឿ ដើមកំណើតជនជាតិ ទំនោរផ្លូវភេទ អាយុ ភេទ វត្តមានអារម្មណ៍ណាមួយ ពិការភាពផ្លូវចិត្ត ឬរាងកាយ ការប្រើឆ្កែនាំផ្លូវ ឬសេវាសត្វដោយមនុស្សពិការ ឬស្ថានភាពអតីតយុទ្ធជន។*

Washington State
Department of Social
& Health Services
*Transforming lives*

DSHS 22-722 CA (Rev. 9/18) Cambodian

# ការណែនាំអំពី ភាពមានសិទ្ធិទទួលបាន ការគាំទ្រ និងសេវាកម្ម



Washington State
Department of Social
& Health Services
*Transforming lives*

រដ្ឋបាលពិការភាពខាងការលូតលាស់

# ភាពមានសិទ្ធិទទួលបាន DDA

ដាក់ពាក្យសុំភាពមានសិទ្ធិទទួលបានរដ្ឋបាលពិការភាពខាងការលូតលាស់ (DDA) បើអ្នក ឬកូនរបស់អ្នកមានមួយក្នុងចំណោមលក្ខខណ្ឌនានាខាងក្រោម។

| ភាពមានសិទ្ធិទទួលបានតាមអាយុ | 0-3 ឆ្នាំ | 4-9 ឆ្នាំ | 10-17 ឆ្នាំ | 18 ឆ្នាំឡើងទៅ |
|---|---|---|---|---|
| មួយការពន្យារពេលខាងការលូតលាស់ | ✓ | | | |
| បី ឬបួនការពន្យារពេលខាងការលូតលាស់ | ✓ | ✓ | | |
| ពិការភាពខាងបញ្ញា | | ✓ | ✓ | ✓ |
| ពិការខួរក្បាល | | ✓ | ✓ | ✓ |
| ជំងឺឆ្កួតជ្រូក | | ✓ | ✓ | ✓ |
| ជំងឺសរសៃប្រសាទ | | ✓ | ✓ | ✓ |
| សរសៃប្រសាទផ្សេងទៀត ឬជំងឺផ្សេងទៀតដែលស្រដៀងនឹងពិការភាពខាងបញ្ញា | | ✓ | ✓ | ✓ |

**ដើម្បីរកឃើញថាមានសិទ្ធិទទួលបាន DDA អ្នកត្រូវតែ ៖**

- ជាអ្នករស់នៅរដ្ឋវ៉ាស៊ីនតោន
- មានភស្តុតាងអំពីពិការភាពខាងការលូតលាស់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចាប់ផ្តើមមុនអាយុ 18 ឆ្នាំ និង
- មានភស្តុតាងនៃដែនកំណត់នានាជាច្រើន។

ស្វែងយល់បន្ថែមអំពីភាពមានសិទ្ធិទទួលបាន DDA នៅ ៖
www.dshs.wa.gov/dda/consumers-and-families/eligibility

**សម្រាប់ព័ត៌មានបន្ថែម**
**ចូលមើលគេហទំព័រ DDA នៅ ៖**
**www.dshs.wa.gov/dda**

# តើសេវាកម្មមួយចំនួនដែល DDA ផ្តល់ឱ្យមានអ្វីខ្លះ?

- អន្តរាគមន៍ដំបូងសម្រាប់កុមារ ពីពេលកើតដល់អាយុបីឆ្នាំ
- ការថែទាំផ្ទាល់ខ្លួន និងការថែទាំសង្គ្រោះ
- ការថែទាំពេលសម្រាក
- ការបណ្តុះបណ្តាលជំនាញលទ្ធកម្ម
- ជំនួយបច្ចេកវិទ្យា
- ការឆ្លើយតបគ្រាអាសន្នផ្ទាល់ខ្លួន
- ការបណ្តុះបណ្តាលការគ្រប់គ្រងអ្នកផ្តល់ការថែទាំ
- សេវាកម្មផ្លាស់ប្តូរសហគមន៍
- ប្រតិភូគិលានុបដ្ឋាយិកា
- គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់
- ការចូលទៅកាន់សហគមន៍
- ការកែប្រែផ្ទះ និងយានយន្ត
- គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់
- សម្លៀកបំពាក់ឯកទេស
- ការប្រឹក្សា និងការគាំទ្រឥរិយាបថ
- ការមើលថែទាំ
- ការចូលរួមក្នុងសហគមន៍
- សេវាកម្មលំនៅដ្ឋាន
- សេវាទប់ស្កាត់វិបត្តិ អន្តរាគមន៍ និងស្ថិរភាព
- ការធ្វើផែនការផ្តោតលើបុគ្គល
- ការគាំទ្រមាតាបិតាសម្រាប់អតិថិជន
- ការណែនាំដៃគូ

# ការចូលរួមក្នុងសេវាកម្ម DDA គឺដោយស្ម័គ្រចិត្ត

DDA ខិតខំអនុវត្តគោលការណ៍សាធារណៈដែលនឹងលើកតម្លៃបុគ្គល គោរពខ្លួនឯង និងសេចក្តីថ្លៃថ្នូរបុគ្គលនីមួយៗគឺមានតម្លៃជាសមាជិកដែលរួមចំណែកនៃសហគមន៍។ មូលនិធិរដ្ឋ និងសហព័ន្ធត្រូវបានប្រើដើម្បីផ្តល់ការគាំទ្រ និងសេវាកម្មសម្រាប់បុគ្គលដែលមានសិទ្ធិទទួល និងក្រុមគ្រួសាររបស់ពួកគេ។ ធនធានគឺមានកម្រិត ហើយសេវាដែលត្រូវការអាចមិនតែងតែរកប្រើបានឡើយ។

**ការចូលប្រើសេវាកម្មនានាផ្អែកលើ ៖**

- ការបំពេញបានតាមតម្រូវការភាពមានសិទ្ធិទទួលបានសម្រាប់សេវាកម្មជាក់លាក់មួយ
- តម្រូវការដែលបានវាយតម្លៃសម្រាប់សេវាកម្ម និង
- មូលនិធិអាចរកបានសម្រាប់សេវាកម្ម។



## សំណួរចោទសួរជាញឹកញាប់

*តើខ្ញុំដាក់ពាក្យសុំភាពមានសិទ្ធិទទួលបាន DDA ដោយរបៀបណា ឬបើខ្ញុំជាអតិថិជន DDA រួចហើយ តើខ្ញុំអាចស្នើសុំសេវាកម្មដោយរបៀបណា?*
ចូរទូរស័ព្ទមកយើងតាមលេខមួយក្នុងចំណោមលេខនៅក្នុងខិត្តប័ណ្ណ ឬចូលទៅលើបណ្តាញនៅ ៖ www.dshs.wa.gov/dda/service-and-information-request។

*តើខ្ញុំអាចស្វែងរកអ្នកផ្តល់សេវាម្នាក់ដោយរបៀបណា?*
**ចម្លើយ ៖** ទាក់ទងអ្នកគ្រប់គ្រងករណីរបស់អ្នក។ ពួកគេអាចផ្តល់ឱ្យអ្នកនូវបញ្ជីអ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬផ្តល់ឧបករណ៍ស្វែងរកដើម្បីកំណត់គោលដៅអ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងតំបន់របស់អ្នក។

*តើ DDA ផ្តល់ជូនសេវាពេលមានវិបត្តិ / គ្រាអាសន្នដែរទេ?*
ប្រសិនបើអ្នកនៅក្នុងដំណើរការដាក់ពាក្យសុំសម្រាប់ភាពមានសិទ្ធិទទួលបាន DDA, DDA អាចជួយជាមួយការបញ្ជូនព័ត៌មាន និងចូលប្រើសេវាកម្មមួយចំនួន ខណៈពេលពាក្យសុំរបស់អ្នកកំពុងត្រូវបានពិនិត្យ។ បើសិនអ្នកមានសិទ្ធិទទួលបាន DDA រួចហើយ ចូរទាក់ទងអ្នកគ្រប់គ្រងករណីរបស់អ្នក។

*តើការគាំទ្រអ្វីអាចរកបានសម្រាប់កុមារក្រោមអាយុបីឆ្នាំ?*
អន្តរាគមន៍ដំបូងត្រូវបានផ្តល់ជាផ្នែកនៃការគាំទ្រដំបូងសម្រាប់ទារក និងកម្មវិធីកូនក្មេងក្នុងភាពជាដៃគូជាមួយនាយកដ្ឋានសិក្សាដំបូង និងទីភ្នាក់ងារនាំមុខក្នុងតំបន់។ ដើម្បីស្វែងយល់បន្ថែម ចូរទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍សុខភាពគ្រួសារតាមលេខ (800) 322-2588 ឬចូលលើបណ្តាញ នៅ ៖ Parenthelp123.org។ សួរអ្នកគ្រប់គ្រងករណីរបស់អ្នកថាតើសេវាផ្សេងទៀតអាចរកបានដែរឬយ៉ាងណា។